ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
Supreme National Economic Council

លេខ: កបស

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ មេសា ឆ្នាំ ២០១៧

**គោរពជូន**

**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយក**

**នៃអគ្គនាយកដ្ឋានពន្ធដារ**

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលជាទីគោរពរាប់អាន!

ខ្ញុំមានទឹកចិត្តរំភើបក្រៃលែង ដោយបានទទួលនូវលិខិតជូនពរសព្ទសាធុការ ពោរពេញទៅដោយមនោសញ្ចេតនារាប់អានខ្ជាប់ខ្ជួន ដែលឯកឧត្តម និងសហការីបានផ្ញើជូនខ្ញុំ ក្នុងឱកាសនៃពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១ ដែលជាទិវាបុណ្យជាតិដ៏ឧត្តុង្គឧត្តមរបស់ប្រជាជនកម្ពុជា។

ខ្ញុំសូមឆ្លៀតយកឱកាសនេះ សំដែងនូវកតញ្ញុតាធម៌យ៉ាងជ្រាលជ្រៅ គោរពជូនចំពោះឯកឧត្តម ដែលបានឧបត្ថម្ភគាំទ្រនៅក្នុងកិច្ចការងាររបស់ខ្ញុំ កន្លងមក។ ជាមួយនេះដែរ ខ្ញុំក៏សូមសម្តែងនូវមូលវិចារណ៍ដ៏ថ្លៃថ្លា និងវាយតម្លៃខ្ពស់ គោរពជូនចំពោះឯកឧត្តម ដែលបាននិងកំពុងដឹកនាំអនុវត្តកំណែទម្រង់ក្នុងវិស័យពន្ធដារប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព សំដៅឱ្យមានការផ្លាស់ប្តូរ និងបានធ្វើឱ្យចំណូលពន្ធមានការកើនឡើងយ៉ាងសម្បើម ស្របតាមយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ របស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។

ក្នុងឱកាសដ៏សែនប្រពៃនេះ ខ្ញុំសូមប្រសិទ្ធិពរបវរមហាប្រសើរ ជូនចំពោះ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល និងក្រុមគ្រួសារ ព្រមទាំងសហការីទាំងអស់ សូមប្រកបដោយសុខភាពល្អបរិបូរណ៍ជានិច្ច សុភមង្គលជាតិយោភាពក្នុងគ្រួសារ បញ្ញាញាណវៃឈ្លាស និងមុតស្រួច ព្រមទាំងសម្រេចបានមហាជោគជ័យថ្មីៗថែមទៀត ក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិ ។

ជាមួយនឹងមនោសញ្ចេតនាគោរពស្រលាញ់ដ៏ជ្រាលជ្រៅនេះ សូមឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល មេត្តាទទួលនូវការរាប់អានកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ

**ប្រធានកិត្តិយសឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ**

**គាត ឈន់**

២០៨ អា.មហាវិថីព្រះនរោត្តម, ខ័ណ្ឌ ចំការមន, រាជធានីភ្នំពេញ
208A, Preah Norodom Blvd, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ: (៨៥៥ ០២៣ ៧២៦ ៤៤៩) ទូរសារលេខ: (៨៥៥ ០២៣ ៧២៦ ៤៤៧)
Phone:(855) 023 726 449, Fax:(855) 023 726 447